# គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

លេខ ០០០៥/១២ .គ.ស.ម

បំរើ ការពារ កសាង

## សេចក្តីថ្លែងការណ៍

**គណបក្សសិទ្ធិមនុស្ស** សូមថ្កោលទោសយ៉ាងម៉ឺងម៉ាត់ចំពោះអំពើហិង្សាដែលបណ្តាលឲ្យអ្នកភូមិ និងកងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលត្រូវរងរបួសជិត 70នាក់ នៅក្នុងការប៉ះទង្គិចគ្នាមួយរវាងប្រជាពលរដ្ឋនៅក្នុងសហគមន៍បូរីកីឡា នាទីក្រុងភ្នំពេញ កាលពីថ្ងៃអង្គារ៍ ទី03 ខែមករា ឆ្នាំ2012 ដែលបង្កឡើងដោយកងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល ក្នុងការបង្ក្រាបយ៉ាងឃោរឃៅទៅលើការតវ៉ាទាមទាររកយុត្តិធម៌ របស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍នេះ ។

ទំនាស់ដីធ្លី និងផ្ទះសម្បែងរវាងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍បូរីកីឡា ជាមួយក្រុមហ៊ុនផានអ៊ីម៉ិចបានកើតឡើងជាងមួយទស្សវត្សរ៍រួចមកហើយ ប៉ុន្តែអាស្រ័យដោយអសមត្ថភាព ឬខ្វះសុឆន្ទៈក្នុងការរកដំណោះស្រាយរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ទើបបណ្តាលឲ្យមានអំពើហិង្សាបានកើតមានឡើងជាបន្តបន្ទាប់ ។

**គណបក្សសិទ្ធិមនុស្ស** គ្មានជំនឿលើរាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដ៏យូរលង់នោះ ថាអាចដោះស្រាយបញ្ហាជម្លោះដីធ្លី ផ្ទះសម្បែង និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរក្រីក្រ ទន់ខ្សោយបានឡើយ ។

អាស្រ័យហេតុនេះ ដើម្បីដោះស្រាយបញ្ហាទាំងនោះដែលរាលដាលទូទាំងប្រទេសរកទីបញ្ចប់មិនឃើញសោះនោះ គឺប្រជាពលរដ្ឋខ្មែរមានតែជម្រើសចុងក្រោយ គឺផ្លាស់ប្តូរអ្នកដឹកនាំបច្ចុប្បន្នតាមគោលការណ៍ប្រជាធិបតេយ្យ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២

គណបក្ស សិទ្ធិមនុស្ស H.R.P. HUMAN RIGHTS PARTY

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*
*ទូរស័ព្ទលេខ ៖ 012 616 616*